ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១២.១២០១/០១/គ.ជ.ប

គណបក្ស សម រង្ស៊ី
នាយកដ្ឋាន រដ្ឋបាល
ចូល | លេខ 198
ថ្ងៃទី 17.12.01
ម៉ោង 14.30

# វិសោធនកម្ម

## ជំពូកទី១០នៃបទបញ្ជា និងនីតិវិធីសម្រាប់កាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ភ្នាក់ងារនៃគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

<u>យោង</u> : - ការចាំបាច់ដើម្បីសម្រួលដំណើរការអនុវត្តការងាររៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- សេចក្តីសម្រេចរបស់អង្គប្រជុំ គជប ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០១ ។

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សម្រេច

ធ្វើវិសោធនកម្មលើចំណុចមួយចំនួនលើជំពូកទី១០នៃបទបញ្ជា និងនីតិវិធីសម្រាប់កាបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ភ្នាក់ងារនៃគណបក្សនយោបាយ និង បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ដែលមានខ្លឹមសារដូចខាងក្រោម ៖

I-<u>ក្នុងជំពូក ទី១០ នៃបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់</u> :

-ចំណុច ១០.៨.៨.៥ (ចាស់ ) ...ឃ្លាទី២ : ក្នុងការអនុវត្តប្រការនេះ អ្នកជំនួយការនៃការិយាល័យ បោះឆ្នោត គប្បីប្រើស្រោមដៃ តែប្រសិនបើគ្មានស្រោមដៃ ត្រូវលាង ដៃឱ្យស្អាតនៅក្រោយ ពេលបិទការិយាល័យបោះឆ្នោត និងមុនពេល រាប់សន្លឹកឆ្នោត ។

-ចំណុច ១០.៨.៨.៥ (ថ្មី ) ...ឃ្លាទី២ : ក្នុងការអនុវត្តប្រការនេះ អ្នកជំនួយការនៃការិយាល័យ បោះឆ្នោត ត្រូវលាងដៃឱ្យស្អាត នៅក្រោយ ពេលបិទការិយាល័យ បោះឆ្នោត និងមុនពេលរាប់សន្លឹកឆ្នោត ។

-ចំណុច ១០.៨.៥.៨ (ចាស់) ត្រួតពិនិត្យលេខបួនខ្ទង់ចុងក្រោយនៅលើប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រ ជំនួសប័ណ្ណបោះឆ្នោត ប្រៀបទៅនឹងលេខកូដការិយាល័យបោះឆ្នោត

រួចណែនាំឱ្យអ្នកបោះឆ្នោតឈរបន្តកន្ទុយគ្នា ប្រសិនបើ គាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

-ចំណុច ១០.៤.៥.៤ ( ថ្មី ) ត្រួតពិនិត្យលេខបួនខ្ទង់ចុងក្រោយនៅលើប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ប្រៀបទៅនឹងលេខកូដការិយាល័យបោះឆ្នោត រួចណែនាំឱ្យអ្នកបោះឆ្នោតឈរបន្តកន្ទុយគ្នាជាពីរជួរ ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

-ចំណុច ១០.៥.៥.៣ .........សម្ភារៈឯកសារបំរើកិច្ចប្រតិបត្តិការបោះឆ្នោតរួមមាន ៖

ចំណុច ● ទី២ (ចាស់) : ផ្លាកលេខសម្គាល់ការិយាល័យបោះឆ្នោត សម្រាប់ បិទលើហិបឆ្នោតចំនួន ១ ។

ចំណុច ● ទី២ ( ថ្មី ): ក្រដាសស ទំហំ A4 ចំនួន៤សន្លឹក សម្រាប់សរសេរលេខសម្គាល់ការិយាល័យបោះឆ្នោត សម្រាប់បិទពីចំហៀងហិបឆ្នោត ។

ចំណុច ● ទី៤ ( ចាស់ ) :សោត្រដោកសម្រាប់ចាក់បិទគម្របខាងក្រៅនៃហិបឆ្នោត ចំនួន ២ ។

ចំណុច ● ទី៤ ( ថ្មី ) :សោត្រដោកសម្រាប់ចាក់បិទគម្របខាងក្រៅនៃហិបឆ្នោត ចំនួន ១ ។

ចំណុច ● ទី១៧(ចាស់) :ស្រោមសំបុត្រតូចចំនួន២ មធ្យមចំនួន៥ និងធំចំនួន១ ដែលត្រូវប្រើយោងតាមចំណុច ១១.១.៤ ១១.១.៥ និង ១១.១.៦ ។

ចំណុច ● ទី១៧( ថ្មី ) : ស្រោមសំបុត្រតូចចំនួន២ មធ្យមចំនួន៦ និងធំចំនួន១ ដែលត្រូវប្រើយោងតាមចំណុច ១១.១.៤ ១១.១.៥ និង ១១.១.៦ ។

ចំណុច ● ទី២១( ចាស់ ) : ទម្រង់បែបបទលេខ ១២០២ ចំនួន៣ក្បាល ក្នុង១ ក្បាលមាន៥០សន្លឹក សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

ចំណុច ● ទី២១( ថ្មី ) :ទម្រង់បែបបទលេខ ១២០២ ចំនួន២ក្បាល ក្នុង១ ក្បាលមាន៥០សន្លឹក សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

ចំណុច ● បន្ថែមថ្មី : ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតចំនួន ១ ។

........សម្ភារៈឯកសារបំរើកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតរួមមាន ៖

ចំណុច ● ទី១ ( ចាស់ ) : ស្រោមសំបុត្រធំ១ និង មធ្យម៣ ដែលត្រូវប្រើយោងតាមចំណុច ១១.៧.១ ។

ចំណុច ● ទី១ ( ថ្មី ) :ថង់ផ្លាស់ស្ទីកធំ១ និងស្រោមសំបុត្រមធ្យម៣ ដែលត្រូវប្រើយោងតាមចំណុច ១១.៧.១ ។

ចំណុច ● ទី៧ : ត្រូវលុបចេញទាំងស្រុង ។

ចំណុច ● ទី១១ : ត្រូវលុបចេញទាំងស្រុង ។

ចំណុច ● បន្ថែមថ្មី :កៅស៊ូកងមួយចំនួនសម្រាប់ចងសន្លឹកឆ្នោត ។

II - <u>ក្នុងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ភ្នាក់ងារនៃគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត</u> :

**ផ្នែក ទី VIII - មធ្យោបាយដឹកជញ្ជូនអ្នកបោះឆ្នោត :**

ចំណុចទី ៣ (ចាស់ ) - កងកម្លាំងប្រដាប់អាវុធដែលមិនស្ថិតក្នុងការបំពេញភារកិច្ច ត្រូវស្លៀកពាក់ស៊ីវិល ដោយគ្មានប្រដាប់អាវុធ ជាតិផ្ទុះណាមួយ ហើយត្រូវធ្វើដំណើរទៅបោះឆ្នោតតាម មធ្យោបាយផ្ទាល់ខ្លួន ។

ចំណុចទី ៣ (ថ្មី ) - កងកម្លាំងប្រដាប់អាវុធដែលមិនស្ថិតក្នុងការបំពេញភារកិច្ច អាចស្លៀកពាក់ស៊ីវិល ឬឯកសណ្ឋានដោយគ្មានប្រដាប់អាវុធ

ជាតិផ្ទះណាមួយ ហើយត្រូវធ្វើដំណើរទៅ បោះឆ្នោតតាម
មធ្យោបាយផ្ទាល់ខ្លួន ។

III -ក្នុងក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត :

**ផ្នែក ទី III -សិទ្ធិ និងភារកិច្ចរបស់អ្នកសង្កេតការណ៍ :**

ចំណុចទី ២៣ (ចាស់ )-ការប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ឬថតសម្លេងនៅក្នុង ការិយាល័យ ចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត ត្រូវហាមឃាត់ ។

ចំណុចទី ២៣ (ថ្មី ) -ការប្រើប្រាស់ម៉ាស៊ីនថតរូប ឬថតវីដេអូ នៅក្នុងការិយាល័យ ចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត ឬការិយាល័យ រាប់សន្លឹកឆ្នោត ត្រូវសុំការអនុញ្ញាត ពីប្រធានការិយាល័យ ។ ការថតរូបភាពនេះមិនត្រូវឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះ ឆ្នោតឡើយ ។

ភ្នំពេញ ថ្ងៃទី 14 ខែ 12 ឆ្នាំ២០០១

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ព្រះរាជាសាស្ត្រាចារ្យ ឆេង - ផុន